ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការកាត់បន្ថយការបាត់បង់ស្រូវ អង្ករ នៅក្រោយពេលច្រូតកាត់






នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
*Department of Agricultural Extension*

អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
N°200 Preah Norodom BVD, Sankat Tonle Basak, Chamkamon, Phnom Penh, Cambodia

ទូរស័ព្ទលេខ : (០២៣) -២១៥ ៨១៩ ទូរសារលេខ : (៨៥៥) ២៣ ២១០ ៩៤៨
Phone : (023) 215 819 Fax : (855) 23 210 948



សហការជាមួយ គម្រោងបង្កើនជីវភាពកសិករក្រីក្រតាមរយៈការធ្វើឱ្យកាន់តែប្រសើរនូវការគ្រប់គ្រងស្រូវបន្ទាប់ពីច្រូតកាត់

ឧបត្ថម្ភបោះពុម្ពដោយ គម្រោងការអភិវឌ្ឍន៍វិស័យកសិកម្ម ADB Project Loan No. 2023-CAM [SF]

## យុទ្ធសាស្ត្រចតុកោណ :

ត្រូវលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម ដោយពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់តាមរយៈការធ្វើប្រពលវប្បកម្ម និងពហុវប្បកម្មកសិកម្ម មានដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងកសិពាណិជ្ជកម្ម ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ ធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ជាពិសេសអង្ករ និងផលិតផលកសិកម្មនានា ។

## ក្រមង៉ុយ :

- ធ្វើស្រែចង់បានស្រូវ ដើមរដូវធ្វើស្រែទួល<br>ស្រែទាបមើលទំនួល លើកទំនប់ឱ្យមាំមួន ។

- ពាក្យចាស់លោកថា ធ្វើស្រែចំការ<br>ស្លាប់មហាសង្ក្រាន្ត ធ្វើម្តងខុសខាត<br>ធ្វើម្តងទៀតបាន ធ្វើតាមប្រមាណ<br>ប្រមើលទឹកភ្លៀង ។

# សេចក្តីផ្តើម:

ដោយខ្វះចំណេះដឹង និងពុំសូវប្រុងប្រយ័ត្នក្នុងការប្រមូល និង គ្រប់គ្រង ធ្វើឱ្យកសិករកម្ពុជាភាគច្រើនជួបប្រទះនូវការបាត់បង់ផលស្រូវ ទាំងបរិមាណ និងគុណភាព ។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) បានរកឃើញថា ចាប់ពីច្រូតកាត់រហូតដល់កិនជាអង្ករ មានការបាត់បង់បរិមាណស្រូវប្រមាណជា ១២% ។ ជាងនោះទៅទៀត វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) បានរកឃើញថា ការធ្វេសប្រហែសក្នុងការគ្រប់គ្រងផលិតផលនេះអាចបណ្តាលឱ្យកសិករខាតបង់រហូតដល់ ៥០% នៃតម្លៃស្រូវសរុបដែលគាត់គួរទទួលបាន ។

ផ្អែកទៅលើព័ត៌មាននេះ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការបច្ចេកទេសពីគម្រោង "ការបង្កើនជីវភាពកសិករក្រីក្រ តាមរយៈការធ្វើឱ្យកាន់តែប្រសើរនូវការគ្រប់គ្រងស្រូវបន្ទាប់ពីច្រូតកាត់ បានរៀបចំចងក្រងនូវឯកសារបច្ចេកទេសនេះសម្រាប់ជាជំនួយដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ក្នុងន័យរួមចំណែកកាត់បន្ថយនូវការបាត់បង់ស្រូវ ក៏ដូចជាកាត់បន្ថយនូវភាពក្រីក្រនៅជនបទផងដែរ ។

ដោយការទទួលបាននូវស្រូវអង្ករច្រើន ហើយប្រកបទៅដោយគុណភាព មានជាប់ទាក់ទងជាមួយកត្តាជាច្រើន ឯកសារនេះបានរៀបរាប់អំពីបច្ចេកទេសសមស្របនានា ចាប់ពីការដាំដុះ រហូតដល់កិនជាអង្ករ ។



## I. ការដាំដុះ និងគ្រប់គ្រងស្រូវអោយបានទិន្នផលខ្ពស់ និងមានគុណភាពល្អ

១. ភ្ជួររាស់ដីឱ្យសព្វ និងស្មើ ដើម្បីឱ្យស្រូវលូតលាស់ និងទុំដំណាលៗគ្នា ហើយគ្រាប់មានទំហំ និងសំណើមប្រហាក់ប្រហែលគ្នា ។

២. ជ្រើសរើសពេលវេលា និងអត្រាដាំដុះឱ្យសមស្រប ។

៣. ជ្រើសរើសកម្រិតដាំដុះឱ្យសមស្រប ព្រោះបើដើមស្រូវដុះញឹកពេក ធ្វើឱ្យវាពុំសូវមាំ (ងាយដួលរលំ) ហើយផ្តល់គ្រាប់តូចៗ ឬ ស្តើងៗ ។ ផ្ទុយទៅវិញ បើដើមរង្វើលពេក ធ្វើឱ្យមានដុះស្ទោចច្រែងច្រើន ឬ មានការបែកគុម្ពខ្លាំង ធ្វើឱ្យគ្រាប់ស្រូវក្នុងគុម្ព ឬ ក្នុងកួរតែមួយមិនអាចទុំបានដំណាលៗគ្នា ។

៤. ដាក់ជីឱ្យស្មើ និងក្នុងពេលសមស្រប ដើម្បីធ្វើឱ្យដើមស្រូវលូតលាស់ និងបែកគុម្ពស្មើៗគ្នា ។



៥. រក្សាឱ្យមានទឹកដក់ក្នុងស្រែស្មើៗជាប្រចាំ និងបង្ហូរចេញមុនពេលច្រូតកាត់ ។



៦. ពិនិត្យមើលដំណាំស្រូវជាប្រចាំ ហើយត្រូវកំចាត់ជម្ងឺ ឬសត្វល្អិត ពីព្រោះវាអាចធ្វើឱ្យគ្រាប់ស្រូវខូចរូបរាង ឬ មានចំណុចអុចខ្មៅៗ។ ដង្កូវរូងដើម